# សុន្ទរកថារបស់ឯកឧត្តម ហូរីណូអ៊ិជិ ហ៊ីដេហ៊ីសា
# ថ្ងៃទី ២៩ ខែកញ្ញា ២០១៧

- សូមគោរព **ឯកឧត្តម ចឹង សុចន្ទា** អភិបាលរងនៃគណៈអភិបាលខេត្តមណ្ឌលគិរី
- សូមគោរព **លោក យន់ សារ៉ោម** ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី
- សូមគោរព **បណ្ឌិត ង៉ោ ប៊ុនថាន** នាយកសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សូមគោរព **បណ្ឌិត MIHARA Machito** នាយកអង្គការERECON
- សូមគោរព **ឯកឧត្តម អ៊ុំ ភូមិរ៉ូ** អគ្គនាយករងអង្គការCMAC
- សូមគោរព **លោក SHIBATA Mikio** ប្រធានតំណាងអង្គការJMAS
- សូមគោរព អស់លោក លោកស្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសប្បាយរីករាយ ដែលបានប្រារព្ធពិធីចុះហត្ថលេខា សម្រាប់គម្រោងជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ និងគម្រោងជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។

ជំនួយទី១ រដ្ឋាភិបាលជប៉ុន នឹងផ្តល់ជូនថវិកាប្រមាណជា ២៤ម៉ឺនដុល្លារអាមេរិក ដល់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី នឹងសាងសង់ស្ពានចំនួន ២ ក្នុងស្រុកកោះញែក ខេត្តមណ្ឌលគិរី។ គម្រោងនេះ ត្រូវបានរំពឹងថា នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណជា ៦,០០០នាក់នៅក្នុងតំបន់។ ខ្ញុំសង្ឃឹមថា ស្ពានថ្មីទាំងពីរនេះ នឹងជួយលើកស្ទួយសេដ្ឋកិច្ចក្នុងតំបន់ តាមរយៈការផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់សាលារៀន មន្ទីរពេទ្យ និងផ្សារជាដើម។

ជំនួយទី២ រដ្ឋាភិបាលជប៉ុន នឹងផ្តល់ជូនថវិកាប្រមាណជា ៥៦ម៉ឺនដុល្លារអាមេរិក ដល់អង្គការERECON។ អង្គការ ERECON នឹងណែនាំកសិករក្នុងខេត្តកំពង់ចាម ដែលជាកន្លែងដាំបន្លែធំជាងគេនៅកម្ពុជា នូវវិធីសាស្ត្រត្រឹមត្រូវក្នុងការប្រើប្រាស់ជីគីមីនិងថ្នាំសម្លាប់សត្វល្អិត និងការប្រើប្រាស់ធនធានធម្មជាតិដែលមិនប៉ះពាល់ដល់បរិស្ថាន ព្រមទាំងបង្កើតប្រព័ន្ធមួយសម្រាប់លក់បន្លែដែលមានប្រើប្រាស់គីមីកសិកម្មតិចតួច ដោយសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត

និងសាកលវិទ្យាល័យនានា។ ខ្ញុំសង្ឃឹមថា ភាពក្រីក្ររបស់កសិករ នឹងត្រូវបានកាត់បន្ថយផលិតផលកសិកម្មប្រកបដោយសុវត្ថិភាពដែលជាតម្រូវការរបស់ប្រជាជន នឹងត្រូវបានដាក់លក់នៅលើទីផ្សារ តាមរយៈការដាំដំណាំប្រកបដោយនិរន្តរភាព និងការលើកកម្ពស់គុណភាពនៃផលិតផលកសិកម្ម។

ជំនួយទី៣ រដ្ឋាភិបាលជប៉ុន នឹងផ្តល់ជូនថវិកាប្រមាណជា ៧៦ម៉ឺនដុល្លារអាមេរិក ដល់អង្គការ JMAS។ អង្គការJMAS នឹងគាំទ្រCMAC ដោយបង្កើតជាគំរូបោសសម្អាតមីនកម្រិតខ្ពស់នៅតំបន់ព្រៃក្រាស់ៗ ក្នុងខេត្តបន្ទាយមានជ័យ ដែលសំបូរទៅដោយមីនប្រឆាំងរថក្រោះ ហើយប្រតិបត្តិការបោសសម្អាតមីនមានស្ថានភាពលំបាក។ ខ្ញុំសង្ឃឹមថា CMAC នឹងអាចបោសសម្អាតមីនក្នុងចម្ការមីនដែលនៅសល់ ហើយលុបបំបាត់ករណីគ្រោះថ្នាក់ដោយសារមីន និងលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចនៅក្នុងតំបន់គោលដៅផងដែរ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថា គម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងប្រទេសកម្ពុជា៕

សូមអរគុណ!